តើអ្វីទៅគឺជាកិច្ចព្រមព្រៀងទទួលប្រាក់ទាំងដុំ?

- ✓ ការទទួលប្រាក់ទាំងដុលគឺជាកិច្ចសន្យារវាងអ្នក និយោជករបស់អ្នក (តាមដែលអាចអនុវត្តបាន) និងក្រុមហ៊ុនធានារ៉ាប់រងសំណងរបស់កម្មករនិយោជករបស់អ្នក។
- ✓ ការទូទាត់តែមួយដងនេះជំនួសមូលទានប័ត្រសំណងប្រចាំសប្តាហ៍របស់អ្នក ហើយក្នុងករណីខ្លះ អត្ថប្រយោជន៍ដទៃមួយចំនួន។
- ✓ ចៅក្រមដែលទទួលករណីប្រាក់ទាំងដុលរបស់អ្នក សម្រេចថាតើការដោះស្រាយការទាមទាររបស់អ្នកគឺនៅក្នុងផលប្រយោជន៍ដ៏ល្អបំផុតរបស់អ្នក។

តើខ្ញុំគួរតែធ្វើករណីទទួលប្រាក់ទាំងដុំរបស់ខ្ញុំឬ?

- ✓ អ្នកត្រូវតែពិចារណាគិតអំពីតម្លៃបច្ចុប្បន្ននៃប្រាក់ទាំងដុំរបស់អ្នកធៀបនឹងអត្ថប្រយោជន៍សក្តានុពល។
- ✓ ប្រសិនបើអ្នកបានរងរបួសនៅថ្ងៃ ឬក្រោយថ្ងៃទី 1 ខែវិច្ឆិកា ឆ្នាំ 1986 អ្នកបោះបង់សិទ្ធិរបស់អ្នកចំពោះអត្ថប្រយោជន៍ប្រចាំសប្តាហ៍នាពេលអនាគត គិតចាប់ពីថ្ងៃដែលការទូទាត់សាច់ប្រាក់របស់អ្នកត្រូវបានអនុម័ត។
- ✓ លើសពីនេះ ប្រសិនបើក្រុមហ៊ុនធានារ៉ាប់រងបានទទួលយកការទទួលខុសត្រូវលើការទាមទាររបស់អ្នក ឬចៅក្រមបានបញ្ជាឱ្យក្រុមហ៊ុនធានារ៉ាប់រងបង់ប្រាក់អត្ថប្រយោជន៍ អ្នកធានាត្រូវទទួលខុសត្រូវក្នុងការចំណាយលើអត្ថប្រយោជន៍ផ្នែកវេជ្ជសាស្ត្រនាពេលអនាគតដែលទាក់ទងនឹងបុព្វហេតុរបស់អ្នក និងការស្តារនីតិសម្បទាវិជ្ជាជីវៈ។
- ✓ ក្រុមហ៊ុនធានារ៉ាប់រងមានសិទ្ធិជំទាស់នឹងវិក្កយបត្រវេជ្ជសាស្ត្រនាពេលអនាគតមុន និងក្រោយកិច្ចព្រមព្រៀងទូទាត់សាច់ប្រាក់របស់អ្នក។

តើការចុះហត្ថលេខាកិច្ចព្រមព្រៀងទទួលប្រាក់ទាំងដុំរបស់ខ្ញុំ មានន័យខ្ញុំក៏ត្រូវបានផ្តាច់ចេញពីការងាររបស់ខ្ញុំឬ?

- ✓ និយោជករបស់អ្នកមិនអាចប្រាប់អ្នកថា តាមរយៈការចុះហត្ថលេខាលើកិច្ចព្រមព្រៀងទទួលប្រាក់ទាំងដុំ អ្នកកំពុងយល់ព្រមមិនត្រឡប់ទៅការងាររបស់អ្នកទេ។

ការចុះហត្ថលេខាកិច្ចព្រមព្រៀងទទួលប្រាក់ទាំងដុំ មិនការពារអ្នកពី៖

- ✓ រក្សាការងាររបស់ខ្លួនជាមួយនិយោជក ដែលនៅការងារនោះ អ្នកត្រូវបានរងរបួស។
- ✓ ទទួលបានការងារថ្មី ជាមួយនិយោជកណាផ្សេងទៀត។
- ✓ ការទទួលបានអត្ថប្រយោជន៍ណាមួយដែលនិយោជករបស់អ្នកជំពាក់អ្នក។
- ✓ នាំយកការទាមទារសំណងរបស់កម្មករនាពេលអនាគតសម្រាប់ការរងរបួស ឬជំងឺទាក់ទងនឹងការងារផ្សេងទៀត; ឬ
- ✓ នាំយកនូវការទាមទារនាពេលអនាគតនៃការបណ្តេញចេញខុស ឬការបំពានកិច្ចសន្យា។

ការសន្មត់ថា និយោជិតដែលទទួលយកប្រាក់ទាំងដុំមួយគឺអសមត្ថភាពក្នុងការត្រឡប់ទៅធ្វើការឱ្យនិយោជកបន្តរយៈពេលមួយខែសម្រាប់រាល់ $1,500.00 រួមបញ្ចូលនៅក្នុងចំនួនប្រាក់ទាំងដុំ។ ដូច្នេះ ប្រសិនបើអ្នកដោះស្រាយករណីរបស់អ្នកក្នុងតម្លៃ $6,000.00 នោះអ្នកនឹងមិនអាច

ត្រឡប់ទៅធ្វើការឱ្យនិយោជករបស់អ្នកវិញក្នុងរយៈពេល 4 ខែ។ នៃ និយោជិតមិនមានសិទ្ធិធ្វើការឡើងវិញក្រោម M.G.L. ក. 152 ក្នុងអំឡុងពេល "សន្នក" នេះ។

នៃ និយោជិតដែលមិនត្រលប់ទៅធ្វើការឲ្យ នៃ និយោជកមុនអាចត្រឡប់ទៅកម្លាំងក្រុមពលកម្មភ្លាមៗ។

- ✓ នៃ នៃយោជក អ្នកជានា នៃង/ឬមេធាវីដែលព្យាយាមឱ្យអ្នកចុះហត្ថលេខាលើប្រភេទនៃការបញ្ចេញ ណាមួយដោយបញ្ជាក់បើមិនដូច្នេះទេ នឹងត្រូវពិន័យជាប្រាក់ $10,000.00 ហើយការដោះលែងបែបនេះ ជាទូទៅ ឬជាក់លាក់នឹងត្រូវចាត់ទុកជាមោយៈ។

តើនិយោជករបស់ខ្ញុំត្រូវតែអនុញ្ញាតប្រាក់ទាំងដុំរបស់ខ្ញុំឬ?

- ✓ ក្នុងករណីភាគច្រើន នៃ នៃយោជកត្រូវតែចុះហត្ថលេខាលើទម្រង់ការយល់ព្រមមុននឹងការយល់ព្រមលើកិច្ចព្រមព្រៀងទទួលប្រាក់ទាំងដុំ ។
- ✓ ក្នុងករណីដែលនៃ នៃយោជកមានសិទ្ធិអំណាចអនុម័ត ប៉ុន្តែមិនយល់ព្រមក្នុងការអនុម័តប្រាក់ទាំងដុំ សំណើនោះមិនដំណើរការទេ។ ក្នុងករណីនេះ អ្នកគប្បីបន្តទទួលអត្ថប្រយោជន៍ប្រចាំសប្តាហ៍របស់អ្នក។

តើសេវាស្តារនីតិសម្បទានឹងប៉ះពាល់ដល់ប្រាក់ទាំងដុំរបស់ខ្ញុំដែរឬទេ?

ប្រសិនបើអ្នកកំពុងទទួលបានសេវាស្តារនីតិសម្បទាវិជ្ជាជីវៈ ប្រាក់ទាំងដុំរបស់អ្នកមិនអាចអនុម័តបានទេ លុះត្រាតែមានតម្រូវការណាមួយក្នុងចំនោមតម្រូវការទាំងនេះ៖

- ✓ អ្នកបានត្រឡប់ទៅធ្វើការវិញ សម្រាប់ 6 ខែឬច្រើនជាងនេះ។
- ✓ អ្នកបានបញ្ចប់កម្មវិធីស្តារនីតិសម្បទាវិជ្ជាជីវៈដែលត្រូវបានអនុម័ត។
- ✓ អ្នកបានទទួលការយល់ព្រមជាលាយលក្ខណ៍អក្សរសម្រាប់OEVR។
- ✓ ចៅក្រមបង្គីសេធរាល់តម្រូវការទាំងនេះ បន្ទាប់ពីមានការជូនដំណឹង និង សវនាការសមស្រប។

- ✓ អ្នកត្រូវតែបញ្ចូលកម្មវិធីស្តារនីតិសម្បទាក្នុងរយៈពេល 104 សប្តាហ៍ចាប់ពី ការយល់ព្រមលើផលប្រយោជន៍របស់អ្នក ឬបាត់បង់សិទ្ធិក្នុងការធ្វើដូច្នេះ។ សម្រាប់ព័ត៌មានបន្ថែមអំពីសេវាកម្មស្តារនីតិសម្បទា សូមទាក់ទង Office of Education and Vocational Rehabilitation (ការិយាល័យអប់រំ និងស្តារនីតិសម្បទា វិជ្ជាជីវៈ) តាមរយៈលេខ (857) 321-7303។

តើការទទួលប្រាក់ទាំងដុំបិទករណីរបស់ខ្ញុំជារៀងរហូតឬ?

- ✓ បាទ/ចាស់ ការទូទាត់ប្រាក់ទាំងដុំជំនួសការទូទាត់សំណងប្រចាំសប្តាហ៍នាពេលអនាគតសម្រាប់ការរងរបួស ឬជំងឺជាក់លាក់នោះ។
- ✓ សិទ្ធិរបស់អ្នកក្នុងការព្យាបាលវេជ្ជសាស្ត្រនាពេលអនាគតនៅតែបើកចំហ ដរាបណាការព្យាបាលវេជ្ជសាស្ត្រនាពេលអនាគតណាមួយសមហេតុផល ចាំបាច់ និងពាក់ព័ន្ធទៅនឹងរបួសរបស់អ្នក។ អ្នកជានាមានសិទ្ធិដដែកតតាំងការព្យាបាលវេជ្ជសាស្ត្រនាពេលអនាគត។

តើការទទួលប្រាក់ទាំងដុំរបស់ខ្ញុំ ប៉ះពាល់ដល់ការទាមទារណាទៀត ដែលខ្ញុំនឹងទទួលឬទេ?

- ✓ ប្រាក់ទាំងដុំមិនប៉ះពាល់ដល់សកម្មភាពផ្សេងទៀត ឬដំណើរការលើរបួស ឬជំងឺដាច់ដោយឡែក និងប្លែកពីគេឡើយ ថាតើរបួស ឬជំងឺកើតឡើងមុន ឬកើតឡើងក្រោយកាលបរិច្ឆេទទូទាត់របស់អ្នក និងមិនគិតពីអ្នកជានា នៃងនិយោជកជានរណា។

តើមេធាវីរបស់ខ្ញុំមានសិទ្ធិទទួលប្រាក់ទាំងដុំចំនួនប៉ុន្មាន?

- ✓ ថ្លៃមេធាវីគឺ 20% ដែលអ្នកជានាទទួលយកការទទួលខុសត្រូវ ឬកន្លែងដែលការទទួលខុសត្រូវត្រូវបានចាត់ចែងដោយនាយកដ្ឋាន។ ថ្លៃមេធាវីគឺ 15% ដែលការទទួលខុសត្រូវមិនត្រូវបានទទួលយក ឬចាត់ចែង។ **មេធាវីមិនអាចប្រមូលថ្លៃសេវាលើការបាត់បង់មុខងារជាអចិន្ត្រៃយ៍ និង/ឬការទូទាត់ ស្លាកស្នាមសេសសល់។**

តើខ្ញុំគួរពិចារណាអ្វីខ្លះនៅពេលកំណត់ថាតើខ្ញុំគួរធ្វើការណីប្រាក់ទាំងដុំរបស់ខ្លួ?

- ✓ តើអ្នកអាចត្រឡប់ទៅធ្វើការវិញឬទេ?
- ✓ តើអ្នកនៅតែមានបញ្ហាវេជ្ជសាស្ត្រដែលមិនអាចដោះស្រាយបានដែលបណ្តាលមកពីរបួស ឬជំងឺរបស់អ្នកទេ?
- ✓ តើការទូទាត់នឹងប៉ះពាល់ដល់វិក្កយបត្រថ្លៃព្យាបាលនាពេលអនាគតដោយរបៀបណា ដែលទាក់ទងនឹងរបួស ឬជំងឺរបស់អ្នក?
- ✓ តើអ្នកនឹងអាចបញ្ជាក់ថារបួសឬជំងឺរបស់អ្នកពាក់ព័ន្ធនឹងការងារឬទេ?
- ✓ តើអ្នកមានប្រាក់ចំណូលប៉ុន្មានឥឡូវនេះបើមាន?
- ✓ តើការចំណាយរបស់អ្នកមានជាអ្វីខ្លះ?
- ✓ តើការទូទាត់នឹងប៉ះពាល់ដល់សិទ្ធិចូលនិវត្តន៍/ប្រាក់សោធននិវត្តន៍របស់អ្នកដែរឬទេ ប្រសិនបើអ្នកមិនត្រឡប់ទៅធ្វើការវិញទេ?
- ✓ ប្រសិនបើអ្នកមានការទាមទារពីភាគីទីបីដែលជាផ្នែកមួយនៃការទាមទារសំណងរបស់កម្មកររបស់អ្នក សូមសួរមេធាវីរបស់អ្នកថាតើវានឹងប៉ះពាល់ដល់ផលប្លកររបស់អ្នក។

កំណត់ចំណាំ៖ "នៅពេលដែលភាគីណាមួយស្នើសុំឱ្យ (កិច្ចព្រមព្រៀងទទួលប្រាក់ទាំងដុំ) ត្រូវបានអនុម័តដោយចៅក្រមរដ្ឋបាល ឬចៅក្រមច្បាប់រដ្ឋបាល មុនពេលដាក់កិច្ចព្រមព្រៀងជាមួយនាយកដ្ឋាននោះ កិច្ចព្រមព្រៀងមួយដុំនឹងមិនត្រូវបានសម្រេចឡើយ លុះត្រាតែមានការយល់ព្រមពីចៅក្រមរដ្ឋបាល ឬចៅក្រមច្បាប់រដ្ឋបាលដែលស្ថិតក្នុងផលប្រយោជន៍ដ៏ល្អបំផុតរបស់អ្នកទាមទារ"។ M.G.L. c. 152, §48 (1).

មានសំណួរឬ? សូមទូរស័ព្ទទៅការិយាល័យព័ត៌មានសាធារណៈរបស់យើង លេខ 617.727.4900។